# ការវាយតំលៃរកមើល  កត្តាដែលមានឥទ្ធិពលទៅលើ “ការមកតាមការណាត់ជួបគ្រូពេទ្យ” របស់កុមារដែលកំពុងប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍

**ផ្នែកអង្កេតតាមដាន**

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

December 24, 2009, Sunway Hotel, Phnom Penh

# សេចក្តីផ្តើម

- ការថែទាំ និង ព្យាបាលជំងឺអេដស៍ គឺជាការថែទាំ និង ព្យាបាលដែលមានរយៈពេលវែង
- មេរោគអេដស៍ ជាមេរោគដែលមាន mutation ខ្ពស់ដែលទាមទារអោយ មានការប្រើប្រាស់ថ្នាំអោយបានត្រឹមត្រូវ ដើម្បីកាត់បន្ថយការកកើតឡើង នូវប្រភេទមេរោគអេដស៍ ដែលមានភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគអេដស៍កំពុងប្រើប្រាស់សព្វថ្ងៃ ។
- ដោយសារមានការលំបាក នៅក្នុងការវាយតំលៃលើការលេបថ្នាំទៀងទាត់ (adherence to treatment) របស់អ្នកជំងឺ អត្រាមកតាមការណាត់ (appointment keeping) ត្រូវបានប្រើប្រាស់ ជំនួសនៅក្នុងការវាយតំលៃនេះវិញ ។

# មូលហេតុដែលនាំអោយមានការវាយតំលៃ

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និង កាមរោគ បានចាប់ផ្តើមអនុវត្តកម្មវិធីបង្ការការកកើតនូវប្រភេទមេរោគអេដស៍ ដែលមានភាពស៊ាំជាមួយ ឱសថប្រឆាំងមេរោគអេដស៍ ចាប់តាំងពីឆ្នាំ ២០០៦
- សកម្មភាពចំបងមួយ ដែលបានអនុវត្ត  ចាប់តាំងពីឆ្នាំ ២០០៨ ដល់ ២០០៩នេះ គឺការប្រមូលសូចនាករមួយចំនួន ដែលទាក់ទងទៅនឹងការកកើតមេរោគអេដស៍ ដែលមានភាពស៊ាំទៅនឹងឱសថប្រឆាំងនៅតាមមណ្ឌលផ្តល់ថ្នាំប្រឆាំងមេរោគអេដស៍ ចំនួន ៤១ កន្លែង ដែលក្នុងនោះ ២៥ កន្លែង មានផ្តល់សេវាសំរាប់កុមារ
- ទិន្នន័យដែលប្រមូលបាន បានបង្ហាញអោយឃើញថា អត្រាមកតាមការណាត់របស់កុមារ នៅតាមមណ្ឌលមួយចំនួន មានកំរិតទាបជាងគោលដៅដែលចង់បាន
- ដូចនេះ ការវាយតំលៃលើ កត្តាដែលទាក់ទងទៅនឹងការណាត់ជួបរបស់កុមារ មានសារៈសំខាន់ណាស់សំរាប់ការកែលំអរសេវា និង ដោះស្រាយបញ្ហា ដែលពាក់ពន្ធ័

# វិធីសាស្រ្តក្នុងការវាយតំលៃ

- ការសំភាសន៏ស៊ីជំរៅ ចំនួន ២៤ នាក់ នៅក្នុងនោះមាន
  - គ្រូពេទ្យព្យាបាលនៅតាមមណ្ឌលផ្តល់សេវាថៃទាំ និងព្យាបាលជំងឺអេដស៏ចំនួន ៤ នាក់
  - អាណាព្យាបាលកុមារ ដែលមានផ្ទុកមេរោគអេដស៏ ហើយបានមកទទួលឱសថប្រឆាំងមេរោគអេដស៏ ចំនួន ២០ នាក់

# ទីកន្លែងដែលធ្វើការវាយតំលៃ

- ខេត្ត កំពង់ឆ្នាំង (នៅមន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង)
- ខេត្តព្រៃវែង (មន្ទីរពេទ្យបង្អែកអ្នកលឿង)
- ខេត្តកំពង់ធំ (មន្ទីរពេទ្យបង្អែកកំពង់ធំ)
- ខេត្តព្រះសីហនុ (មន្ទីរពេទ្យបង្អែកចំការចេក)

# លក្ខដល

# កត្តាសំខាន់ៗដែលលើកយកមកវាយតំលៃ

- កត្តាដែលធ្វើអោយអ្នកជំងឺ មិនអាចមកទទួលថ្នាំបានទៀងទាត់
- កត្តាដែលធ្វើអោយអ្នកជំងឺ អាចមកទទួលថ្នាំបានទៀងទាត់

# កត្តាដែលធ្វើអោយអ្នកជំងឺមិនអាចមកទទួលថ្នាំបានទៀងទាត់

- អ្នកជំងឺមាន ស្ថានភាពគ្រួសារខ្សត់ខ្សោយ និង មានចំណេះដឹងទាប
- កង្វះការគាំទ្រ និង ការសំរបសំរួលពីក្រុមគ្រូពេទ្យ ទាក់ទងនឹងការពិនិត្យជំងឺ និង បែបបទរដ្ឋបាល និង ការណាត់ជួបរបស់គ្រូពេទ្យ
- មានការរើសអើង និង កង្វះការជួយគាំទ្រផ្សេងៗ ពីសហគមន៍
- ទទួលបានសេវាពីមណ្ឌលផ្តល់ថ្នាំដែលនៅឆ្ងាយពីផ្ទះ

# ការលំបាកនៅក្នុងគ្រួសារ

- កត្តាគ្រួសាររបស់កុមារ

  - កង្វះអ្នកជួយមើលថែទាំ និងយកចិត្តទុកដាក់ដល់កុមារ

  “ហើយដល់ពេលត្រូវបើកថ្នាំខ្ញុំទៅបើកថ្នាំខ្លួនឯង ព្រោះម៉ែខ្ញុំគាត់រវល់ស៊ីឈ្នួលធ្វើការងារគេ”

  - ស្ថានភាពជាកុមារកំព្រា

  “ខ្ញុំមើលពនាក់លោកគ្រូ ហ្នឹងសុទ្ធតែកូនក្មួយទេហ្នឹង ម៉ែវាប្អូនជីដូនមួយ តែវាកំព្រា តាំងពីតូច វាគឺជាកូនរបស់ក្មួយបង្កើត ឃើញវាកំព្រាអត់ម៉ែឪ វាមករស់នៅជាមួយ ខ្ញុំតាំងពីតូច ម៉ែវាក៏អត់មានម៉ែឪដែរ ម៉ែឪក្មេងនេះលែងលះគ្នា ៣ ឆ្នាំហើយ ហើយ ម្តាយគ្នាអត់ដឹងថានៅរស់ ឬ ស្លាប់ទេ មិនដឹងថានៅដេរកើត ឬ អត់ដែរ ចំណែកឪពុកវាក៏អញ្ចឹងដែរ”

# ការលំបាកនៅក្នុងគ្រួសារ

- ស្ថានភាពគ្រួសារមានការលំបាក ជាពិសេសលើផ្នែកជីវភាព

“ជីវភាពខ្ញុំសព្វថ្ងៃនេះ មានសភាពយ៉ាប់ជាងមុនឆ្ងាយណាស់ (យំនិយាយមិនចេញ) អត់មាន នរណា ឧបត្ថមទេ តែក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ កាលខ្ញុំចេញពីពេទ្យសៀមរាបនេះ គាត់អោយទឹកដោះគោ ហ្នឹងប្រហែលជា ៨ កុំប៉ុងមក បានអានោះឯង រាល់ថ្ងៃនេះខ្ញុំមានផ្ទុកដែរ”

- ជីវភាពមានភាពប៉ះពាល់ខ្លាំង ដោយសារមានកុមារផ្ទុកមេរោគក្នុងបន្ទុក

“ខ្ញុំតាំងពីយកកូននេះ មកលក់អស់ហើយទាំងនៅលើត្រចៀក និងខ្សែករ នៅដៃអីអស់ហើយ សូម្បីតែស្លៀកពាក់ក៏មិនហ៊ានទិញដែរ”

# ឥរិយាបថ និង ចំណេះដឹងរបស់អាណាព្យាបាលកុមារ

- អ្នកជំងឺក្មេងពេកពិបាកលេបថ្នាំ

“ជួនកាលទៅចិត្តវាស្រួលទៅលេបទៅ ជួនកាលមិនស្រួលទៅ យើងលួងលោមវាទៅបញ្ជោវាទៅបានលេបទៅ” ។

- មិនអាចមើលដឹងថ្ងៃណាត់ជួបរបស់គ្រូពេទ្យបាន

“កាលពីមុនខ្ញុំខ្មាស់គេ ដល់ឥឡូវ ខ្ញុំអត់ចេះអក្សរពេលណាខ្ញុំត្រូវបើកថ្នាំ ខ្ញុំដើរបង្ហាញកាតគេ ដើម្បីសួររកថ្ងៃគ្រូពេទ្យ ណាត់ ខ្ញុំលែងខ្មាស់គេហើយ”

- មិនដឹងពីថ្នាំ និង របៀបប្រើថ្នាំ

“ មិនដែលមានធ្វើអ្វីចំណាំទេ មានតែមើលនៅក្នុងកូនសៀវភៅពេទ្យអោយហ្នឹង មិនដឹងថា ធ្វើអីផង”

“ពេលលេបថ្នាំ ខ្ញុំចំណាំពណ៌ថ្នាំទៅ ពេលដែលពេទ្យអោយខ្ញុំហ្នឹង”

# ការលំបាកនៅតាមមណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍

- ការណាត់ដែលមិនបានផ្តល់ភាពងាយស្រួល

"ខ្ញុំមកទទួលថ្នាំមានការយឺតយ៉ាវញឹកញាប់ដែរ ដោយសារខ្ញុំអត់មានសាហ៊ុយ ហើយខ្ញុំ និងប្រពន្ធខ្ញុំក៏មានផ្ទុកដែរ ហើយពួកខ្ញុំបានទទួលថ្នាំពន្យាហើយ ហើយបានបើកថ្នាំនៅកំពង់ធំនេះឯង ខ្ញុំ និងប្រពន្ធបើកថ្នាំត្រូវគ្នា តែកូនខ្ញុំបើកពេល ផ្សេងពីខ្ញុំនិងប្រពន្ធ ដូច្នេះខ្ញុំត្រូវមកពីរដង"

"ពេទ្យជាអ្នកអោយគាត់បើកកុមារផ្សេង មនុស្សចាស់ផ្សេងមិនអាចបើក ត្រូវគ្នាបានទេ ព្រោះអីចាំមើលតិចទៀត ចាំគាត់ជ្រេរអោយ តែរាល់ថ្ងៃមនុស្សច្រើន ដូច ថាណាត់ត្រូវថ្ងៃច្រើនគ្នា ចំគ្នាពេក គាត់អត់ទាន់សម្រួលអោយមកជាមួយគ្នាបានទេ ខ្ញុំសុំ គាត់ពីរដងហើយ ប្រាប់គាត់ហើយថាអត់មានសាហ៊ុយ តែគាត់ថា ចាំមើលខែក្រោយអី ក្រែងល គាត់អាចសំរួលអោយមកជាមួយគ្នាបាន តែខ្ញុំសុំគាត់ប៉ុន្មានដងហើយអត់ បានទេ" ។

# ការលំបាកនៅតាមមណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍

- កង្វះគ្រូពេទ្យនៅមណ្ឌល

"ទៅហ្នឹងបានថ្ងៃតែមួយទេ គ្រាន់តែម៉ោងហ្នឹងជួនកាលម៉ោង ១២ ជួនកាល ម៉ោង ១១កន្លះទៅ ព្រោះពេទ្យទាល់តែគាត់ទំនេរពីខាងនោះ ហើយបានគាត់មកបើក មើលអោយ យើង" ។

- រយៈពេលរង់ចាំយូរ

"ខ្ញុំមកពីម៉ោង ៧ ដល់នេះប្រហែលជាម៉ោង៨ ដល់នេះ ម៉ោង១០ ជាងទើបបើកបាន។ បានថាខ្ញុំសុំសំណូមពរគ្រូពេទ្យ ហើយខ្ញុំនៅចុង កាត់ មាត់ញូកបើកពេលវេលាអោយបានរហ័ស អោយទាន់ម៉ូតូឌុបគេ បើហួសម៉ោងអត់មានអីជិះទេ មានថ្ងៃមួយអត់មានអីជិះដើរ២នាក់ចៅ តាំងពីក្បាល ថ្នល់ដល់ម៉ោង ៨-៩ យប់បានដល់ផ្ទះ អត់មានអីជិះទេ ដើរអត់បាយស៊ីទេ ទៅដល់ផ្ទះដេកគ្រឹបអត់មានស៊ីបាយទេ" ។

# ការលំបាកនៅតាមមណ្ឌលផ្តល់សេវាផែនការ និងព្យាបាលជំងឺអេដស៍

- មិនអាចបើកថ្នាំបានគ្រប់ចំនួន ក្នុងពេលមកកាន់មណ្ឌលក្នុងខែនីមួយៗ

"បាទមានដែរ ជួនកាលខ្លះទៅលោកគ្រូពេទ្យគាត់អោយយើងទៅ គាត់ដូចថា ថ្ងៃណាត់ៗថ្ងៃខាងមុខមែនតែគាត់ ប្រាប់ថាថ្ងៃនេះ ត្រូវមកយកថ្នាំព្រោះថ្នាំវាខ្វះអញ្ចឹង ដល់ថ្ងៃគ្រូពេទ្យប្រាប់អញ្ចឹង យើងមកយកទៅបានហើយ"

- គ្រូពេទ្យមិនបានជួយរកវិធីសាស្រ្តអ្វីសំរាប់ចំណាំថ្ងៃណាត់ជួបអោយមានប្រសិទ្ធិភាព

"ខ្ញុំសរសេរលើសៀវភៅថ្ងៃណាត់នេះ គាត់មានកូនសៀវភៅមួយ យើងបានប្រាប់គាត់ពី ថ្ងៃដែលគាត់ត្រូវមកហើយ ឯវិធីចងចាំខ្ញុំអត់ដឹងទេ ខ្ញុំបានប្រាប់គាត់តែអញ្ចឹង បើគាត់ អត់ចេះអក្សរឧបមាថា ផ្ទះគាត់មានកូនធំៗអោយសួរកូនទៅ បើគាត់អត់ចេះអក្សរ យ៉ាងហោចណាស់ក៏គាត់ចេះមើលអក្សរដែរ ភាគច្រើនបើអត់ចេះមើលអក្សរ ក៏ចេះមើលលេខដែរ អានេះយើងប្រាប់ហើយ ក្រែងលោគ់ភ្លេចយើងប្រាប់ថា រៀបមកមើលសៀវភៅផង យើងចង្អុលអាថ្ងៃណាត់ហ្នឹង យើងតែងតែណែនាំគាត់" ។

# ការលំបាកនៅក្នុងសហគមន៍

- ការរើសអើងនៅក្នុងសហគមន៍

“ជីវភាពខ្ញុំសព្វថ្ងៃនេះ អ្នកគ្រូខ្ញុំចង់តែស្លាប់ទេ ព្រោះពិបាកពេកកំសត់ណាស់ (គាត់ស្រែកទ្រហូយំខ្លាំងៗ) បែទៅចៅមាន ផ្ទុកមេរោគហើយអត់មានអណ្តូងប្រើ ពេលទៅផ្ទះគេៗមិនអោយ ប្រើទៀត គេមិនអោយ ងូតទឹកអណ្តូងគេទេ កំសត់ណាស់ សំភារៈសិក្សា និងខោអាវហ្នឹង អង្គការចិត្តធមិ គេ ជួយអោយរហូត មាន អង្គការគេផ្តល់អោយហូបចុក ហើយនិយាយថា ចាំមើលកាលដល់ផ្តាច់ចាំគាត់ប្រាប់ ខ្ញុំអង្វរគាត់ថា អ្នកគ្រូ កុំអាលផ្តាច់ព្រោះចៅនៅតូចណាស់” ។

- កង្វះការគាំទ្រ ផ្នែករដ្ឋបាល

“បើយើងចង់ធ្វើសំបុត្រធ្វើអី គេធ្វើអោយ តែគេយកលុយដែរ ព្រោះជាតំរូវការរបស់គេសព្វថ្ងៃទៅ ហើយ” ។

# ការលំបាកនៅក្នុងសហគមន៍ (ត)

- មានការខ្មាស់អៀនពេលមកទទួលថ្នាំ

  “ខ្ញុំគិតថាខ្មាស់ ហើយកាលពីមុនខ្ញុំខ្មាស់គេមែនទែន ខ្ញុំមកបើកថ្នាំពាក់ម៉ាសពាក់អី អត់អោយគេឃើញ តែឥឡូវ ខ្ញុំមិនគិតអញ្ចឹងទេ ព្រោះនេះជាជំងឺរបស់ខ្ញុំមែន ព្រោះ ខ្ញុំគិតថាឪពុកម្តាយគេមាន មានសុភមង្គល ហើយគ្រួសារខ្ញុំក្រហើយមានជំងឺអញ្ចឹងទៀត ខ្ញុំមានអារម្មណ៍ខ្មាស់គេមែនទែន” ។

- មានការរើសអើងអាចនាំអោយការផ្លាស់ប្តូរទីលំនៅច្រើន ដែលអាចប៉ះពាល់ដល់ការទទួលសេវា

  “ម៉ាភូមិកោះកែវហ្នឹងគេខ្ពើមគ្រប់គ្នា ព្រោះឃើញខ្ញុំដៃជើងអញ្ចឹង( ចេញរមាស់ពាក់ស្រោមដៃជាប់) ខ្ញុំអត់ហ៊ានប្រាប់គេទេ ។ តែអ៊ុំខ្ញុំម្នាក់ទៀត គាត់ដឹង ម៉ែខ្ញុំប្រាប់គាត់ តែគាត់លាក់ការដែរ ម៉ែថាបើគេដឹងនៅភូមិនេះទៀត គាត់អត់នៅភូមិហ្នឹងទៀតទេ” ។

# ទីតាំងរបស់មណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍ និងការធ្វើដំណើរ

- មណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍ ស្ថិតនៅឆ្ងាយពីផ្ទះ

“នៅភូមិ ត្បែង ឃុំត្រពាំងស្រែ ស្រុកមេសាង ពីផ្ទះមកកន្លែងបើកថ្នាំនេះ ៩០-១០០ គីឡូម៉ែត្រ” ។

“ពីផ្ទះខ្ញុំមកកន្លែងនេះ ៤៨-៥០គីឡូម៉ែត្រពេលខ្ញុំធ្វើដំណើរមកបើកថ្នាំនេះ ខ្ញុំមកពីផ្ទះ ជិះម៉ូតូ ដល់លើថ្នល់ទើប ជិះឡានមកតទៀត”

- ស្ថានភាពផ្លូវមានភាពលំបាក

“មកនេះទឹកហូកាត់ថ្នល់ ហើយពេលដាច់ខ្ញុំត្រូវធ្វើដំណើរនេះ បើពេលខែវស្សាលំបាក ត្រូវជិះផ្លូវវាងអញ្ជឹង ខ្ញុំត្រូវធ្វើដំណើរតាំងពីព្រឹកដល់ថ្ងៃរសៀលទើបមកដល់ទីនេះ ជួនកាលទៅទាន់ ម៉ោងជួនកាលទៅ មិនទាន់ពេទ្យស្តីអោយទៀត បើខែប្រាំងមិនអីទេ” ។

# កង្វះការគាំទ្រផ្សេងៗទៀត

- គ្មានក្រុមថែទាំតាមផ្ទះ  សំរាប់ជួយមណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍

“ដូចខ្ញុំជំរាបអ្នកគ្រូហើយ ថាកន្លែងខ្ញុំសព្វថ្ងៃអត់មានដៃគូអីទាំងអស់ អញ្ចឹងអ្នកជំងឺ កាលណាមកក៏ឃើញទៅ បើគាត់អត់មកក៏មិនដឹងធ្វើម៉េចដែរ ព្រោះយើងអត់មានថ្លៃ ទូរសព្ទ័ អត់មានអីហៅគាត់ អត់មានអីទាំងអស់ ទូរសព្ទ័កន្លែងហ្នឹង និយាយទៅ អត់ មានដៃគូរមកជួយសហការណ៏ អត់មាន ដល់អញ្ចឹងគាត់មកក៏មកឃើញ គាត់មិនក៏ បាត់ទៅ មិនដឹងធ្វើម៉េច មិនដឹងទៅរកនៅឯងណាដែរ” ។

# កត្តាដែលធ្វើអោយអ្នកជំងឺអាចមកទទួលថ្នាំបានទៀងទាត់

- ការមានគ្រួសារដែលជួយគាំទ្រ, ជីវភាពគ្រួសារល្អ អាណាព្យាបាល រឺ កុមារមាន ឥរិយាបថល្អ និង ចំណេះដឹងខ្ពស់
- គ្រូពេទ្យមាន ឥរិយាបថល្អចំពោះអ្នកជំងឺ និង ផ្តល់ភាពកក់ក្តៅដល់អ្នកជំងឺពេល ដែលគាត់មកទទួលសេវា
- មានការធ្លាក់ចុះនូវការរើសអើង ក្នុងសហគមន៏
- អ្នកជំងឺមានភាពងាយស្រួលទៅកាន់មន្ទីរពេទ្យ រឺ មានលទ្ធភាពក្នុងការធ្វើដំណើរ ទៅទទួលសេវា ដោយមិនមានការប៉ះពាល់ដល់ជីវភាពគ្រួសារ

# កត្តាគ្រួសារ

- មានអ្នកដាស់តឿនអោយលេបថ្នាំ និងមានការទទួលខុសត្រូវខ្ពស់

  “បើពេលណាចៅដេកជ្រុលខ្ញុំដឹងតែស្រែកហៅវាអោយក្រោកឡើង ដើម្បីលេបថ្នាំ ឪពុកម្តាយរបស់ចៅហ្នឹងវាមិនបានដឹង ពីការស្លាប់របស់គ្នា ទៅវិញ ទៅមកទេ ខ្ញុំ ទៅយកមក ហ្នឹង វាប្រហែលជា ៥-៦ឆ្នាំ យកមកហ្នឹងចេះតែក្អកយប់ឡើងចេះតែក្អកគេ” ។

- មានមុខរបរ ធ្វើជាអ្នកស្មគ្រ័ចិត្ត

  “មានការងារធ្វើទាំងប្តី ទាំងប្រពន្ធ ខ្ញុំធ្វើការជាអ្នក ស្ម័គ្រនៅកន្លែងបើកថ្នាំនេះ”

# ឥរិយាបថ និង ចំណេះដឹងរបស់អាណាព្យាបាលកុមារ

- ទុកអាយុជីវិតរបស់ខ្លួនជារឿងសំខាន់

"បើអត់មានគេជួយ ខ្ញុំនៅតែមកបើកថ្នាំនេះដែរ ព្រោះកូនខ្ញុំផ្ញើរជីវិតនៅលើថ្នាំហើយ យើងត្រូវតែមកហើយ ទោះអត់មាន ត្រូវតែមានហើយពេលនេះ" ។

- អាចមើលសៀវភៅបាន

"ខ្ញុំរាល់ថ្ងៃនេះ មើលនៅក្នុងសៀវភៅដែល ពេទ្យសរសេរណាត់អោយ ខ្ញុំចេះអានបាន ហើយខ្ញុំទៅណាមកណា ខ្ញុំសរសេក្រដាស់មួយដាក់នៅហោប៉ៅខ្ញុំ"

- ការយល់ដឹងពីការប្រើប្រាស់ថ្នាំ

"គឺខ្ញុំចំណាំពណ៌ថ្នាំ ហើយតាមគាត់ពន្យល់ទៀត ខ្ញុំអាចចាប់បានច្បាស់តែម្តង"

# ការគាំទ្រពីសហគមន៍

- ការរើសអើងនៅក្នុងសហគមន៍មានការថយចុះ

  “ចំពោះការលក់ដូរមុនដំបូងពិបាកដែរ ដូចថា ខ្ញុំធ្វើនំ ធ្វើចំណីអីលក់ លក់អត់ដាច់ដែរ គេអត់ចង់ស៊ីទេ គេហៅអេដស៍អីអញ្ចឹង ខ្លាចឆ្លងអេដស៍ ដល់ឥឡូវអត់អីទេ លក់ដូរ ដូចគេឯងអញ្ចឹង មានតិចតួចខ្លះរិះគន់អញ្ចឹងដែរ តែមានតិចទេ ដូចថា ១០នាក់ មាន១នាក់អីអញ្ចឹងទេ” ។

- មានការគាំទ្រពីសហគមន៍ និងសាលារៀន

  “មានអង្គការជួយនៅសាលាគេអោយអាហារូបករណ៍សំរាប់អ្នកកើតអេដស៍ ខ្ញុំប្រលងជាប់អាហារូបករណ៏ គឺបាន ១ឆ្នាំ ១៨ម៉ឺន” ។

# ការគាំទ្រផ្សេងៗទៀត

- ការជួយផ្នែកជីវភាពរស់នៅ និងក្រុមថៃទាំតាមផ្ទះ

“អ្នកដែលជួយនោះគឺខាង CLA អង្គការរបស់បងជាតិហ្នឹង មានអង្គការពីរដែលជួយខ្ញុំ មានជាថវិកាសំលៀកបំពាក់ សំភារៈសិក្សា ស្បែកជើង ថវិកាសំរាប់ទិញម្ហូបអាហារ គឺ ៤ ម៉ឺនរៀលក្នុងមួយខែ”

“មានគឺបងភា និងបងជាតិជាអ្នកជួយជុំរុញអោយខ្ញុំមក គាត់ទៅជួយលើកទឹកចិត្ត និង ទៅមើលថ្នាំខ្ញុំជារៀងរាល់ខែ មិនដឹងថាគាត់ធ្វើអីទេ គ្រាន់តែដឹងថា គាត់ទៅជួយលើក ទឹកចិត្តខ្ញុំ ( ក្រុមថៃទាំតាមផ្ទះ)”

# ឥរិយាបថគាំទ្ររបស់គ្រូពេទ្យ

- ពន្យល់លើការប្រើប្រាស់ថ្នាំ និងធ្វើអោយអ្នកជំងឺមានភាពកក់ក្តៅរាល់ពេលមកទទួលសេវា

“ហៃលោកគ្រូសំដីល្អណាស់ សួរសុខទុក្ខរហូត ឃើញចាប់អោយចាប៉ិតក្មេង លោកគ្រូពេទ្យ ទាំងស្រីទាំងប្រុស ស្រឡាញ់ណាស់ មិនដែលមានពពាក្យតូចធំអីចេះ ចុះ គំរាមកហ៊ើញអីអត់ សោះហើយ ។ គ្រូពេទ្យនិយាយប្រាប់ដែរ លោកគ្រូនិយាយ ប្រាប់ពីរឿងអោយក្មេងថៃក្មេង អោយលេបថ្នាំទៀងទាត់ គឺទូន្មានតែអញ្ចឹង ខ្ញុំថាអូ លោកគ្រូពេទ្យ កុំភ័យរឿងត្រង់ហ្នឹង ខ្ញុំខ្លាចណាស់ ខ្ញុំអោយលេបទៀងទាត់ណាស់ ពេទ្យនៅកន្លែងបើកថ្នាំពន្យល់ថា ថ្នាំនេះត្រូវលេបព្រឹក អោយទៀង ហើយនិងថ្ងៃត្រង់ និងល្ងាចអោយទៀងទាត់កុំអោយលេបខកខាន បើលេបម៉ោង ៨ ម៉ោង៩មេរោគក្នុងខ្លួនត្រូវចេះហើយដឹងថ្នាំទៀតដាក់ទៅមិនត្រូវទៀតទេ” ។

# ទីតាំងរបស់មណ្ឌលផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍ និង ការធ្វើដំណើរ

- ផ្ទះនៅជិតកន្លែងទទួលថ្នាំ

  "ប្រហែលជា២០០ម៉ែត្រ ខ្ញុំដើរមកប្រហែល ២០ នាទី"

# សេចក្តីសន្និដ្ឋាន

- កុមារដែលមានអ្នកជួយមើលថែទាំ អាចទទួលថ្នាំ និង លេបថ្នាំបានទៀងទាត់
- កុមារដែលរស់នៅក្នុងគ្រួសារ ដែលមានជីវភាពក្រីក្រនឹងមានឥទ្ធិពលជាអវិជ្ជមានទៅលើការទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍
- អាណាព្យាបាលកុមារ ដែលដឹងពីថ្ងៃណាត់ជួបមានភាពងាយស្រួលក្នុងការនាំកុមារមកទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍បានទៀងទាត់
- ការផ្តល់ពិតមានពីការប្រើប្រាស់ថ្នាំអោយបានច្បាស់លាស់ អាចជួយអោយអាណាព្យាបាលកុមារអាចផ្តល់ថ្នាំ អោយកុមារបានត្រឹមត្រូវ និងទៀងទាត់

# សេចក្តីសន្និដ្ឋាន

- ការណាត់ជួប ដែលអាចអោយកុមារដែលមានផ្ទុកមេរោគ និង អាណាព្យាបាលមកទទួលថ្នាំក្នុងថ្ងៃតែមួយ អាចជួយសន្សំសំចៃថវិកា និង ជួយអោយកុមារបានទទួលថ្នាំបានទៀតទាត់
- គ្រូពេទ្យដែលបានប្រាប់ ថ្ងៃណាត់ជួបបានច្បាស់លាស់ ដល់អាណាព្យាបាលកុមារ អាចជួយអោយកុមារបានមកទទួលថ្នាំទៀងទាត់
- ការដែលបានទទួលថ្នាំ ពីមណ្ឌល ដែលនៅជិតអាចធ្វើអោយអត្រាមកទទួលឱសថទៀងទាត់ មានការកើនឡើង

# សេចក្តីសន្និដ្ឋាន

- សហគមន៍ ដែលមានការរើសអើងទាប រឺ គ្មានការើសអើង ជួយអោយកុមារអាច ទទួលបានសេវាថែទាំ និងព្យាបាលជំងឺអេដស៏បានទៀតទាត់
- ការផ្តល់ការគាំទ្រនៅតាមសាលា និង ការថែទាំតាមផ្ទះ ជាកត្តាសំខាន់ក្នុងការជួយ ជំរុញអោយកុមារបានទទួលថ្នាំបានទៀងទាត់ ។

# អនុសាសន៍

- ការចូលរួមគាំទ្ររបស់ក្រុមគ្រូពេទ្យ មានសារៈសំខាន់ណាស់ ក្នុងការធ្វើអោយប្រសើរឡើង នូវអត្រាមកតាមការណាត់របស់អ្នកជំងឺ
- ការណាត់ដែលអាចអោយ កុមារមានផ្ទុកមេរោគ និងអាណាព្យាបាលរបស់កុមារអាចមកទទួលសេវាជាមួយគ្នា គឺជំរុញអោយកុមារមានឱកាសទទួលថ្នាំបានទៀងទាត់
- គ្រូពេទ្យគួរចំណាយពេលបន្ថែម ដើម្បីធ្វើការពន្យល់អោយអាណាព្យាបាលបានយល់ច្បាស់ពីការប្រើប្រាស់ថ្នាំ ដើម្បីជួយអោយអាណាព្យាបាលកុមារអាចផ្តល់ថ្នាំដល់កុមារបានត្រឹមត្រូវតាមការណែនាំ

# អនុសាសន៍

- កុមារដែលមានអ្នកថែទាំត្រឹមត្រូវ មានអត្រាមកតាមការណាត់ជួបខ្ពស់ និង បានលេបថ្នាំតាមការណែនាំ ដូចនេះ កម្មវិធីសុខភាពគួរផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើអាណាព្យាបាលកុមារ ដែលកំពុងប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ ។
- សកម្មភាពរបស់ក្រុមថែទាំតាមផ្ទះ គួរផ្តោតការយកចិត្តទុកដាក់ លើការរំលឹកថ្ងៃណាត់របស់អ្នកជំងឺ និង ការប្រើប្រាស់ថ្នាំប្រឆាំងមេរោគអេដស៍ ។
- គួរធ្វើការពិនិត្យឡើងវិញ លើបញ្ហាកង្វះថវិកាធ្វើដំណើរមកទទួលថ្នាំរបស់កុមារមានផ្ទុកមេរោគអេដស៍ ដើម្បីឆ្លើយតបនឹងបញ្ហា ដែលកុមារត្រូវមកកាន់មណ្ឌលផ្តល់ថ្នាំលើសពីមួយដងក្នុង ១ ខែ

# អនុសាសន៍

- ការចូលរួមរបស់សហគមន៍ សាលារៀន និងអាជ្ញាធរមូលដ្ឋាន ដើម្បីកាត់បន្ថយភាពរើសអើងទៅនឹងអ្នកជំងឺអេដស៍ ជាពិសេសទៅនឹងកុមារ ក៏អាចផ្តល់លទ្ធផលជាវិជ្ជមានទៅលើការទទួលថ្នាំបានទៀងទាត់ ។
- ពង្រីកសកម្មភាពនានា ដែលជំរុញអោយជីវភាពគ្រួសារ របស់អ្នកមានផ្ទុកមេរោគអេដស៍ រឺ គ្រួសារ ដែលមានកុមារមានផ្ទុកមេរោគអេដស៍ក្នុងបន្ទុក មានភាពប្រសើរឡើង អាចជាដំណោះស្រាយល្អ សំរាប់រយៈពេលវែង។

# សូមអរគុណ